**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**

# សារជូនពរ

**សូមគោរពជូន**

**សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា**

**ក្នុងពិធីចម្រើនជន្មាយុគម្រប់ ៨១ ឈានចូល ៨២ ឆ្នាំ**

**២៥.៥.១៩៣៤ - ២៥.៥.២០១៥**

តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ ព្រមទាំងនាយទាហាន នាយទាហានរង និងពលទាហាន នៃកងយោធពលខេមរភូមិន្ទទាំងមូល និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមសម្តែងនូវមនោសញ្ចេតនាសោមនស្សរីករាយយ៉ាងក្រៃលែង ចូលរួមអបអរសាទរយ៉ាងស្មោះស្ម័គ្រអស់ពីដួងចិត្តចំពោះទិវាដ៏នក្ខតឫក្ស នៃពិធីចម្រើនជន្មាយុគម្រប់ **៨១** ឈានចូល **៨២** ឆ្នាំរបស់ **សម្តេច** នាថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៥ នេះ។

**សម្តេចអគ្គមហាពញាចក្រី ប្រធានរដ្ឋសភា ជាទីគោរពដ៏ខ្ពង់ខ្ពស់** !

ស្ថិតក្នុងឱកាសនៃទិវាដ៏ឧត្តុង្គឧត្តមនេះ សូម **សម្តេច** មេត្តាអនុញ្ញាតឲ្យយើងខ្ញុំទាំងអស់គ្នាសម្តែងនូវសេចក្តីគោរពប្រកបដោយកតញ្ញូតាធម៌ និងស្វាមីភក្តិយ៉ាងជ្រាលជ្រៅបំផុត ចំពោះគុណូបការៈដ៏ធំធេងពុំអាចកាត់ថ្លៃបានរបស់ **សម្តេចអគ្គមហាពញាចក្រី ប្រធានរដ្ឋសភា** ដែលបានបូជាអស់កម្លាំងកាយចិត្ត ប្រាជ្ញាស្មារតី ក្នុងបេសកកម្មក្នុងប្រទេសក្រៅប្រទេស ដើម្បីបុព្វហេតុបម្រើជាតិមាតុភូមិ និងប្រជាពលរដ្ឋធ្វើឲ្យកិត្យានុភាពព្រះរាជាណាចក្រកម្ពុជាល្បីរន្ទឺលើឆាកអន្តរជាតិ។

ជាកិច្ចតបស្នងចំពោះគុណូបការៈ និងស្នាដៃដ៏ឧត្តុង្គឧត្តមថ្លៃថ្លានេះ យើងខ្ញុំទាំងអស់គ្នាជាកងយោធ-ពលខេមរភូមិន្ទ សូមអនុញ្ញាតសម្តែងនូវមនោសញ្ចេតនា ចូលរួមអបអរសាទរប្រកបដោយសមានចិត្តសោមនស្សរីករាយជាអនេកប្បការជូនចំពោះ **សម្តេច** នឹងសូមប្តេជ្ញាការពាររដ្ឋសភាជាតិ ដែលជាស្ថាប័នកំពូលរបស់រដ្ឋមិនឲ្យនរណាម្នាក់បំផ្លាញបានជាដាច់ខាត។

ទន្ទឹមនឹងជោគជ័យប្រកបដោយក្តីមោទនភាពជាតិដ៏ឧត្តុង្គឧត្តមនេះ យើងខ្ញុំទាំងអស់គ្នាជា កងយោធ-ពលខេមរភូមិន្ទ សូមធ្វើការកោតសរសើរស្ញប់ស្ញែងដោយសុទ្ធចិត្តបំផុតជូនចំពោះ **សម្តេច** ដែលជានិច្ចកាលតែងតែប្រកាន់ខ្ជាប់ខ្លួនក្នុងភាពចាស់ទុំនយោបាយ មានឆន្ទៈមនសិការ បញ្ញាញាណភ្លឺថ្លាក្នុងការអភិវឌ្ឍស្ថាប័ន នីតិប្បញ្ញត្តិរបស់ជាតិ អនុវត្តធានាបាននិរន្តរភាពប្រជាធិបតេយ្យ និងនីតិរដ្ឋនៅកម្ពុជា។

នាឱកាសដ៏វិសេសវិសាលនេះ យើងខ្ញុំសូមប្រសិទ្ធិពរជ័យ សិរីមង្គល វិបុលសុខមហាប្រសើរ ជូន **សម្តេច** និង**លោកជំទាវ** ព្រមទាំងបុត្រ បុត្រធីតា ចៅៗ និងក្រុមគ្រួសារសូមមានសុខភាពល្អបរិបូរណ៍ ជន្មាយុយឺនយូរ និងសូមឲ្យបានជួបប្រទះតែនឹងពុទ្ធពរ បួនប្រការ គឺ **អាយុ វណ្ណៈ សុខ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចអគ្គមហាពញាចក្រ** និង**លោកជំទាវ** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ។

សេចក្តីគួរពុំគួរ សូមសម្តេចមេត្តាអភ័យទោស

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែឧសភា ឆ្នាំ ២០១៥

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**នាយឧត្តមសេនីយ៍ ទៀ បាញ់**